# មជ្ឈមណ្ឌលឯកសារកម្ពុជា

**សម្ភាសន៍ជាមួយ ទូច ធុល ភេទប្រុស អាយុ៥៥ឆ្នាំ**

**មុខងារសម័យខ្មែរក្រហមៈ "យោធា"**

**ស្រុកកំណើតនៅភូមិស្ពោអែម ឃុំចំបក់ ស្រុកបាទី ខេត្តតាកែវ**

**រស់នៅភូមិទំនប់ដាច់ ឃុំទំនប់ដាច់ ស្រុកត្រពាំងប្រាសាទ ខេត្តឧត្តរមានជ័យ**

**ថ្ងៃទី២៤ ខែវិច្ឆិកា ឆ្នាំ២០១៣**

**សម្ភាសន៍ដោយៈ សុខ វណ្ណៈ**

**០០:៤៩:០០**

**២១ទំព័រ**

វណ្ណៈ៖ ចឹងថ្ងៃហ្នឹងថ្ងៃទី២៤ខែ១១ឆ្នាំ២០១៣ ចឹងខ្ញុំឈ្មោះ សុខ វណ្ណៈ មកពីអង្គការមជ្ឈមណ្ឌលឯកសារកម្ពុជា ។

ធុលៈ បាទ ។

វណ្ណៈ៖ អង្គការខ្ញុំមានទីតាំងនៅភ្នំពេញ ជាអង្គការក្រៅរដ្ឋាភិបាលអត់មានទាក់ទងជាមួយបញ្ហានយោបាយអីទេ ចឹងខ្ញុំមកដល់ភូមិឃុំអ៊ីគឺចង់ដឹងប្រវត្តិរឿងរ៉ាវដែលកើតមានឡើងដែលអ៊ីធ្លាប់ឆ្លងកាត់តាំងពីតូចមក ។

ធុលៈ បាទ ។

វណ្ណៈ៖ មកដល់បច្ចុប្បន្នថាហេតុអីបានជាដូចថាអ្នកខ្លះមានស្រុកកំណើតនៅកំពង់ចាម ខ្លះនៅតាកែវ ខ្លះកំពត កំពង់ស្ពឺ ហេតុអីបានជាពួកគាត់មករស់នៅជាយដែន ខេត្តឧត្តរមានជ័យនេះវិញ ដោយសារមានរឿងរ៉ាវអីខ្លះបានជាពួកគាត់នៅទីនេះហើយមិនបានទៅស្រុកកំណើតវិញ ចឹងហើយបានជាខាងខ្ញុំចង់រឿងរ៉ាវទាំងអស់ហ្នឹងយកមកចងក្រងជាឯកសារទុកជាប្រវត្តិសាស្ត្រ ដើម្បីឲ្យក្មេងជំនាន់ក្រោយបានដឹងថា ស្រុកយើងជួបរឿងរ៉ាវជាច្រើនមានដំណាក់កាលបេះមួយៗដែលនាំឲ្យមនុស្សមករស់នៅចឹង ។

ធុលៈ បាទ ។

វណ្ណៈ៖ ចឹងបទសំភាសខ្ញុំជាមួយអ៊ីហ្នឹង តើអ៊ីមិនថាអីទេ?

ធុលៈ បាទ ។

វណ្ណៈ៖ ចឹងអាចឲ្យខាងខ្ញុំយកទៅចងក្រងជាឯកសារបាន?

ធុលៈ បាន តែខ្ញុំនិយាយបានតិចៗទេ ។

វណ្ណៈ៖ បាទ!មិនអីទេ កន្លែងណាដែលអ៊ីបានដឹងអ៊ីនិយាយទៅកន្លែងណាអ៊ីមិនបានដឹងក៏មិនអីដែរ ។

ធុលៈ បាទ ។

វណ្ណៈ	ចឹងជាដំបូងខ្ញុំចង់ស្គាល់ឈ្មោះ អ៊ំ អ៊ំឈ្មោះអីដែរ?

ធុលៈ	ខ្ញុំឈ្មោះ ទូច ធុល ។

វណ្ណៈ	អ៊ំមានឈ្មោះហៅក្រៅទេ?

ធុលៈ	អត់ទេ ។

វណ្ណៈ	អ៊ំអាយុប៉ុន្មានហើយ?

ធុលៈ	អាយុ៥៥ឆ្នាំ ។

វណ្ណៈ	ប្រពន្ធអ៊ំឈ្មោះអីដែរ?

ធុលៈ	ឈ្មោះ សុខុម ។

វណ្ណៈ	គាត់អាយុប៉ុន្មានដែរ?

ធុលៈ	គាត់អាយុ៤៧ ។

វណ្ណៈ	អ៊ំមានកូនប៉ុន្មាននាក់សព្វថ្ងៃ?

ធុលៈ	កូនមាន៥នាក់ ។

វណ្ណៈ	ស្រីប៉ុន្មានប្រុសប៉ុន្មាន?

ធុលៈ	ស្រី៤ប្រុស១ ។

វណ្ណៈ	អ៊ំរៀបការនៅឆ្នាំណាដែរ?

ធុលៈ	ខ្ញុំរៀបការនៅឆ្នាំ១៩៨៧ ប្រពន្ធមុនវាជិតរត់ចោល ចឹងកូនបីនៅជាមួយខ្ញុំទាំងអស់ ។

វណ្ណៈ	ចឹងប្រពន្ធមួយទៀតនោះការឆ្នាំណា?

ធុលៈ	ប្រពន្ធមួយទៀតការឆ្នាំ១៩៩៧ ។

វណ្ណៈ	ចឹងប្រពន្ធទី១ការឆ្នាំ៨៧?

ធុលៈ	បាទ ។

វណ្ណៈ	ចឹងប្រពន្ធទី២ការឆ្នាំ៩៧?

ធុលៈ	បាទ ។

វណ្ណៈ	ចឹងជិតសម័យសមាហរណ៍កម្មដែរ?

ធុលៈ	បាទ!ជិតមានសមាហរណ៍កម្ម ។

វណ្ណៈ	ចឹងកូនអ៊ំរាល់ថ្ងៃហ្នឹងមានរៀបការបែកផ្ទះហើយនៅ?

ធុលៈ	បានមួយ ។

វណ្ណៈ	ចឹងហ្នឹងឈ្មោះអីទៅ?

ធុលៈ	ឈ្មោះ នី ។

វណ្ណៈ	កូនប្រុសស្រី?

ធុលៈ	ស្រី ។

វណ្ណៈ	ឥឡូវគាត់ទៅនៅណាហើយ?

ធុលៈ	ឥឡូវផ្ទះវានៅខាងនោះ ។

វណ្ណៈ	ជិតនេះដែរ?

ធុលៈ	ជិតនេះ ។

វណ្ណៈ	ចឹងឪពុករបស់អ៊ឹឈ្មោះអីដែរ?

ធុលៈ	ខ្ញុំឪពុកខ្ញុំឈ្មោះ ទូច ថន ។

វណ្ណៈ	ចឹងម្ដាយ?

ធុលៈ	ម្ដាយឈ្មោះ ទា ខន ។

វណ្ណៈ	ចឹងរាល់ថ្ងៃហ្នឹងលោកទាំងពីរនៅរស់ដែលអត់?

ធុលៈ	គាត់ស្លាប់អស់ហើយ ។

វណ្ណៈ	ស្លាប់ជំនាន់ណា?

ធុលៈ	គាត់ស្លាប់ដោយចាស់ឈឺ ។

វណ្ណៈ	ចឹងបងប្អូនមានប៉ុន្មាននាក់?

ធុលៈ	បងប្អូនអត់មានទេ មានតែម្នាក់ឯងហ្នឹង ។

វណ្ណៈ	ចឹងអ៊ឹកូនទោលតែម្ដង?

ធុលៈ	បាទ ។

វណ្ណៈ	ចឹងអ៊ឹមានភូមិកំណើតនៅណាដែរ?

ធុលៈ	ភូមិស្ដៅអែម ។

វណ្ណៈ	ឃុំ?

ធុលៈ	ឃុំចំបក់ ស្រុកបាទី ខេត្តតាកែវ ។

វណ្ណៈ	ចឹងកាលពីតូចអ៊ឹបានរៀនសូត្រដល់ណាដែរ?

ធុលៈ	អ៊ឹកាលពីតូចបានរៀនដល់ថ្នាក់ទី៨ដែរ ដល់ហើយឈប់រៀននៅពេលមានបាតុកម្មរដ្ឋប្រហារទៅ ។

វណ្ណៈ	ចឹងទី៨“ចាស់”នៅសាលាបឋមសិក្សាអីគេដែរ?

ធុលៈ	សាលាបឋមសិក្សាអង្គសិន ។

វណ្ណៈ	ចឹងមូលហេតុឈប់រៀនហ្នឹងដោយសារកើតមានរដ្ឋប្រហារ?

ធុលៈ ដោយសាររដ្ឋប្រហារ មានពីណារៀនទៀតរត់អស់ ។

វណ្ណៈ ចឹងកើតរដ្ឋប្រហារឈប់រៀននៅឆ្នាំ១៩៧០ ?

ធុលៈ បាទ! នៅឆ្នាំ១៩៧០ ។

វណ្ណៈ ចឹងពេលឈប់រៀនមកជួយធ្វើស្រែចម្ការឪពុកម្តាយឬក៏ចូលចលនា?

ធុលៈ បាទ!ឈប់រៀនមកជួយធ្វើស្រែចម្ការ ។

វណ្ណៈ អត់ទាន់ចូលចលនាតស៊ូអីទេ?

ធុលៈ នៅទេ កាលហ្នឹងវាយគ្នារហូតហ្នឹងយើងនៅក្មេងៗ ។

វណ្ណៈ ចឹងនៅពេលដែលអ៊ំមកផ្ទះធ្វើស្រែចម្ការហ្នឹងអ៊ំមានជួបហេតុការណ៍អីខ្លះទេ?

ធុលៈ នៅស្រុកដូចជាអត់មានហេតុការណ៍អីផង មានតែយន្តហោះទម្លាក់ ។

វណ្ណៈ ទម្លាក់ឆ្នាំណាអ៊ំមានដឹងទេ?

ធុលៈ កាលទម្លាក់ឆ្នាំណាទេ ដូចជាឆ្នាំ៧០យន្តហោះអាបេ៥២អីហ្នឹង ។

វណ្ណៈ ចឹងកាលដែលមានយន្តទម្លាក់ហ្នឹងអ៊ំមានដឹងថាមានគ្រោះថ្នាក់អីខ្លះដែរ?

ធុលៈ បើភូមិហ្នឹងដូចជាមិនអី តែភូមិគេព្រុថាមានរបួសមានអី ភូមិគេផ្សេងៗមាន ភូមិខ្ញុំអត់មានទេ កាលហ្នឹង មានតែរណ្តៅបេច្រើន ។

វណ្ណៈ ចឹងក្រោយពីមានទម្លាក់គ្រាប់បែករយៈពេលពីរបីឆ្នាំហ្នឹង នៅក្នុងភូមិអ៊ំមានអ្នកមកឃោសនាឲ្យចូលចលនាបដិវត្តឬមានស្តាប់តាមការប្រកាសរបស់សម្តេចឪតាមវិទ្យុថាឲ្យកូនចៅចូលព្រៃម៉ាគីអីទេ?

ធុលៈ កាលហ្នឹងព្រុចាស់ៗចូលព្រៃម៉ាគី តែកាលនោះខ្ញុំនៅតូចៗមិនបានយកចិត្តទុកដាក់អីទេ ។

វណ្ណៈ ចឹងកាលហ្នឹងអ៊ំអាយុប្រហែលជាប៉ុន្មាន?

ធុលៈ កាលហ្នឹងខ្ញុំអាយុទើបតែ១២ទៅ១៣ប៉ុណ្ណឹង ។

វណ្ណៈ ចឹងមិនបានចូលចលនាទេ?

ធុលៈ បាទ!អត់ទេ ។

វណ្ណៈ ចឹងរហូតដល់ឆ្នាំណាបានអ៊ំបានចូលចលនា?

ធុលៈ ដល់ឆ្នាំ៧៥ ។

វណ្ណៈ ចឹងឆ្នាំ៧៥ពេលដាច់ភ្នំពេញហើយហ្នឹង?

ធុលៈ បាទ!ដាច់ភ្នំពេញហើយហ្នឹង គេមកយកទៅតែម្តង ។

វណ្ណៈ ខែប៉ុន្មានអ៊ំមានដឹងទេ?

ធុលៈ ភ្លេចហើយ មិនដឹងខែណាទេ ក្មេងដែលមិនសូវចាំ ។

វណ្ណៈ៖ ចឹងឆ្នាំ៧៥ហ្នឹងមានខាងណាទៅជ្រើសរើសយក?

ធុលៈ ខាងខ្មែរក្រហម ។

វណ្ណៈ៖ ចឹងមេភូមិមេឃុំមេស្រុក?

ធុលៈ មេភូមិហ្នឹង អ្នកមានកូនប្រុសៗចឹងគេដើរប្រមូលទៅបញ្ចូលទ័ពចឹងទៅ ។

វណ្ណៈ៖ ចឹងកាលហ្នឹងឪពុកម្ដាយអ៊ីអនុញ្ញាតដែលព្រោះគាត់មានកូនតែមួយចឹង?

ធុលៈ បាទ!មិនអនុញ្ញាតយ៉ាងម៉េចបើគេត្រូវតែយកទៅចឹងហើយ ។

វណ្ណៈ៖ ចឹងមានន័យថា បង្ខុំអ៊ីអត់មានចង់ចូលទេ?

ធុលៈ អាហ្នឹងចូលបង្ខុំហើយ ។

វណ្ណៈ៖ ចឹងកាលហ្នឹងអ៊ីមានចិត្តចង់ទៅដែរ?

ធុលៈ អត់ទេ ព្រោះយើងអត់មានស្គាល់សង្គ្រាមផង តែដូចថាប្រធានភូមិចឹងគេថាមានកូនឲ្យចូលកងទ័ព កាលហ្នឹងគេឈ្នះហើយណា អាហ្នឹងដូចជាបង្ខុំដែលបើយើងមិនទៅមិនបាន បើអត់ទៅបានខ្ញុំនៅផ្ទះបាត់ហើយ ។

វណ្ណៈ៖ ចឹងតាមពិតមិនចង់ចូលទៅទេ?

ធុលៈ មិនចង់ទេ ។

វណ្ណៈ៖ ណាមួយឪពុកម្ដាយមានកូនតែមួយទៀត?

ធុលៈ បាទ!ដល់ចឹងខ្លាចចេះចុះដែរ ដល់ចឹងខ្លាចអំណាចគេ ។

វណ្ណៈ៖ ចឹងកាលគេមកជ្រើសរើសយកដំបូងចេញពីផ្ទះហ្នឹងគេឲ្យអ៊ីទៅកន្លែងណាដំបូង គេយកទៅដាក់នៅកន្លែងណា?

ធុលៈ មុនដំបូងយកទៅកន្លែងឃុំគេ ។

វណ្ណៈ៖ យកមកឃុំអ៊ីរស់នៅឃុំចំបក់ហ្នឹងមិនមែន?

ធុលៈ អត់ទេ គេយកមកខេត្តកណ្ដាលវិញហើយ គេយកទៅហាត់ទាហាននៅវត្តជើងកុក ។

វណ្ណៈ៖ ចឹងយកចេញភ្លាមយកទៅខេត្តកណ្ដាលតែម្ដង?

ធុលៈ ហ្នឹងហើយយកទៅខេត្តកណ្ដាល យកទៅហាត់រីកហ៊ឺននៅវត្តជើងកុកខេត្តកណ្ដាលវិញ ។

វណ្ណៈ៖ ចឹងពេលហាត់រៀននៅហ្នឹងឃើញមានយោធាច្រើនទេ ដែលកំពង់ហាត់ហ្នឹង?

ធុលៈ ប្រហែលជា២០០នាក់ក្មេងៗ តែក្មេងៗសុទ្ធតែម្ដង ។

វណ្ណៈ៖ ចឹងក្មេង២០០នាក់ហ្នឹងមកពីគ្រប់ភូមិ?

ធុលៈ មកពីគ្រប់ភូមិមកចូលកន្លែងហ្នឹង មកហាត់រីកហ៊ឺនចឹងទៅណា ។

វណ្ណៈ៖ ចឹងពេលមកដល់កន្លែងហ្នឹងប្រធានកងពលពីណាគេ?

ធុលៈ កាលហ្នឹងមិនបានដឹងទេ ថាមេកងសាលាហ្នឹង កងពលខ្ញុំមិនបានដឹងទេ ស្គាល់តែមេសាលាទេ ស្គាល់គ្រូបង្ហាត់ផ្នែកយោធា ផ្នែកនយោបាយចឹងទៅណាស់ ។

វណ្ណៈ ហាត់បានរយៈពេលប៉ុន្មានដែរ?

ធុលៈ ហាត់បានរយៈពេលបីខែ ។

វណ្ណៈ ចឹងកាលហ្នឹងអត់បានដឹងថានៅកងពល៧០៣ប្រធានកងពលឈ្មោះ តា ណាត អត់មានដឹងទេ?

ធុលៈ មិនដឹងថា កងពលអីខ្ញុំអត់ដឹងដែរ កងពល១២-១១ខ្ញុំអត់ចាំដែរ ។

វណ្ណៈ អ៊ំអត់មានដឹងថានៅកងពលមួយណាទេ?

ធុលៈ អត់ចាំទេ ។

វណ្ណៈ អត់ដឹងថានៅ១១ឬ១២?

ធុលៈ អត់ដឹង ខ្ញុំមិនសូវជាយកចិត្តទុកដាក់មិនចាប់អារម្មណ៍ ។

វណ្ណៈ ចឹងកាលគ្រូបង្ហាត់ហ្នឹងគាត់ឈ្មោះអី?

ធុលៈ ភ្លេចហើយវាយូរពេក ។

វណ្ណៈ ចឹងហាត់បានបីខែហើយគេបញ្ជូនអ៊ំទៅខាងណាទៀត?

ធុលៈ គេបញ្ជូនមកចម្ការដូង ។

វណ្ណៈ ចម្ការដូងភ្នំពេញហ្នឹងអ៊ំនៅធ្វើអីកន្លែងហ្នឹង?

ធុលៈ នៅកន្លែងហ្នឹងចាប់ផ្ដើមហាត់យោធានិងនយោបាយ ។

វណ្ណៈ ចឹងហាត់យោធាទៀត?

ធុលៈ បាទ!ហាត់យោធា ហាត់លូនហាត់អីហើយធ្វើស្រែ ។

វណ្ណៈ ចឹងពេលហាត់រត់លូនរួចឲ្យធ្វើស្រែវិញ?

ធុលៈ បាទ!ធ្វើស្រែកាប់ចប ។

វណ្ណៈ ធ្វើស្រែនៅណា?

ធុលៈ ធ្វើនៅព្រៃស ។

វណ្ណៈ ហើយពីណាប្រធានកាន់កាប់នៅហ្នឹង?

ធុលៈ អត់ស្គាល់ ។

វណ្ណៈ ចឹងអត់មានដឹងថាកងពលណាទេ?

ធុលៈ អត់ដឹងទេ មានមេកងសាលា តែមិនបានដឹងថាឈ្មោះអីៗអត់ចាំណា ។

វណ្ណៈ ចឹងកាលពូធ្វើស្រែនៅរោងចក្រកែវ នៅព្រៃសអីហ្នឹងបានដល់ឆ្នាំទេ?

ធុលៈ បានប្រហែលជាមួយវស្សាយើងហ្នឹង ប្រហែលជាមួយខែពីរខែចឹងទៅ ។
វណ្ណៈ ចឹងធ្វើនៅហ្នឹងបានមួយវស្សាពីរវស្សាចឹងទៅណាទៀត?
ធុលៈ បានតែមួយខែពីរខែទេ គេបញ្ជូនទៅរតនគិរីបណ្ដោយ ។
វណ្ណៈ ចឹងបញ្ជូនទៅខេត្តរតនគិរីនៅឆ្នាំ១៩៧៥ដដែលឬឆ្នាំ៧៦ហើយ?
ធុលៈ នៅឆ្នាំ៧៥ដដែលហ្នឹង ។
វណ្ណៈ ចឹងកាលពេលអ៊ឹនៅខាងខេត្តរតនគិរីជិះអីទៅ?
ធុលៈ យើងជិះទូកធំៗទៅចេញពីភ្នំពេញ ។
វណ្ណៈ ជិះទូកដល់ត្រឹមណា?
ធុលៈ ជិះទូកដល់ត្រឹមខេត្តក្រចេះ សម្រាកនៅហ្នឹងបានប្រហែលមួយខែបានឡើងឡានទៅដល់ស្រុកបាលុង ។
វណ្ណៈ ចឹងពេលធ្វើដំណើរចេញទៅខេត្តរតនគិរីហ្នឹងអស់រយៈពេលប៉ុន្មានថ្ងៃដែរ?
ធុលៈ មើលចេញពីភ្នំពេញនៅសម្រាកនៅក្រចេះមួយខែ ចេញពីក្រចេះទៅមួយយប់បានដល់បាលុង ។
វណ្ណៈ ទៅដល់បាលុងឬវឺនសៃ?
ធុលៈ ទៅដល់បាលុង ចឹងយក្សឡោមហើយបានបន្តទៅស្រុកវឺនសៃ ។
វណ្ណៈ ចឹងទៅហ្នឹងកាលអ៊ឹចេញពីក្រចេះទៅមានគ្នាប៉ុន្មានរយនាក់ប៉ុន្មានពាន់នាក់ដែរ មានប៉ុន្មានឡានទៅ?
ធុលៈ កម្លាំងកាលហ្នឹងមានប្រហែលជា៥០០នាក់ ។
វណ្ណៈ កម្លាំងហ្នឹងចំរុះមកពីគ្រប់តំបន់ឬមានតែកម្លាំងមកពីខាងខេត្តតាកែវទេ ឬមួយមានកម្លាំងមកភូមិភាគបូព៌ា មានខាងពាយ័ព្យ មានខាងខត្តរទៅជាមួយដែរ?
ធុលៈ កម្លាំងថ្មីហ្នឹងមានចំរុះ ។
វណ្ណៈ ចឹងពេលទៅដល់ខេត្តរតនគិរី វឺនសៃហ្នឹងអ៊ឹមានដឹងថានៅក្នុងកងពលអីទេ?
ធុលៈ ទៅដល់ហ្នឹងដឹងហើយនៅកងពល៨០១ មានហើយ ។
វណ្ណៈ ពីណាប្រធានកងពល?
ធុលៈ តា០៥ ។
វណ្ណៈ តាសារឿន?
ធុលៈ បាទ ។
វណ្ណៈ ចឹងកាលហ្នឹងអនុមានពីណាគេ?

ធុលៈ　　មិនដឹងជាពីណាទេ វាមានច្រើនវគ្គច្រើនស្មើពេក មួងអ្នកនេះមួងអ្នកនោះទៅ ។

វណ្ណៈ　　យ៉ាងម៉េចបានជាមានច្រើនពេកចឹង?

ធុលៈ　　ចឹងបានថា ដូចជាប្រធានវរសេនាធំចឹងដកគ្នាចឹងទៅដាក់អ្នកថ្មីមកវិញហើយ កាលហ្នឹងតាស៊ុន ដែរ ។

វណ្ណៈ　　តាស៊ុន ក្រោយមកដឹងថាគេចាប់ខ្លួនគាត់ដែរ កាលហ្នឹងប្រធានកងពលឬអ្នកមានឋានៈអីច្រើនតែបាត់ខ្លួនដែរ?

ធុលៈ　　បាទ ។

វណ្ណៈ　　ចឹងកាលដែលអ៊ំទៅដល់នៅកងពល៨០១ហ្នឹង កាលហ្នឹងអ៊ំជាយុទ្ធជនឬមានឋានៈជាប្រធានវរសេនាតូចវរសេនាធំអីទេ?

ធុលៈ　　អត់ទេ កាលហ្នឹងយើងនៅក្មេងៗ ។

វណ្ណៈ　　ចឹងកាលហ្នឹងទៅដល់ដំបូងមានចាញ់ឈឺស្លាប់ទេ?

ធុលៈ　　មានចាញ់ ឈឺស្លាប់ ។

វណ្ណៈ　　ចឹងកាលហ្នឹងមានឈឺស្លាប់ច្រើនទេ?

ធុលៈ　　គ្រុនចាញ់ស្លាប់ច្រើនណាស់ ។

វណ្ណៈ　　ចឹងកាលហ្នឹងកងទ័ពនៅបាលុងនៅវឺនសៃហ្នឹងគេឲ្យទៅការពារព្រំដែនជាមួយវៀតណាមឬគេឲ្យទៅធ្វើស្រែកាប់ព្រៃអីយ៉ាងម៉េច គេការពារអីខ្លះនៅហ្នឹង?

ធុលៈ　　ការពារខាងឡាវ ពួកខ្ញុំការពារខាងឡាវ អ្នកនៅសមរភូមិក្រោយធ្វើស្រែ ។

វណ្ណៈ　　ចឹងកាលហ្នឹងអ៊ំមានតួនាទីការពារព្រំដែនឡាវ អ្នកនៅក្រោយធ្វើស្រែ?

ធុលៈ　　បាទ ។

វណ្ណៈ　　ចឹងប្រធានវរៈអ៊ំមានស្គាល់ទេ?

ធុលៈ　　ប្រធានវរៈគាត់ស្លាប់អស់ហើយ ។

វណ្ណៈ　　គាត់មានឈ្មោះអីទៅ?

ធុលៈ　　ឈ្មោះ តាឡូញ ។

វណ្ណៈ　　គាត់ជាវរសេនាតូចឬសេនាធំ?

ធុលៈ　　វរសេនាតូច ។

វណ្ណៈ　　ចឹងកាលដែលអ៊ំការពារព្រំដែនឡាវហ្នឹង អ៊ំការពារកុំឲ្យឡាវចូលមកទឹកដីខ្មែរឬការពារខ្មែរដែលប្រុងរត់ទៅប្រទេសគេ?

ធុលៈ　　ការពារកុំឲ្យគេចូលមកទឹកដីយើង ។

វណ្ណៈ:	ចឹងអ៊ឹមានឃើញខ្មែរយើងរត់កាត់តាមច្រកហ្នឹងដើម្បីទៅរស់នៅស្រុកគេទេ?

ធុលៈ	អត់មានទេ តាមច្រកហ្នឹង ។

វណ្ណៈ:	ចឹងកាលហ្នឹងជីវភាពខាងកងទ័ពហ្នឹងយ៉ាងម៉េចដែរ?

ធុលៈ	កាលហ្នឹងយើងហូបគួរសមដែរ វាមិនមានការខ្វះខាតទេ ។

វណ្ណៈ:	ចឹងពេលឈឺគេបញ្ជូនមកសមរភូមិក្រោយឬមានពេទ្យចាំព្យាបាលនៅនោះតែម្តង?

ធុលៈ	ពេទ្យមានប្រចាំការនៅហ្នឹងមួយកន្លែង ។

វណ្ណៈ:	ចឹងកាលទៅដំបូងមិនទាន់មានថ្នាំព្យាបាលត្រូវស្លាប់ច្រើន?

ធុលៈ	បាទ!ស្លាប់ច្រើនដំបូងមិនទាន់មានថ្នាំព្យាបាលត្រូវ ។

វណ្ណៈ:	ចឹងកាលដែលអ៊ឹទៅដល់ដំបូងហ្នឹងឃើញព្រៃឈើច្រើនធំៗ ហើយមានសត្វព្រៃសម្បូរទេ?

ធុលៈ	កាលហ្នឹងមានព្រៃឈើច្រើននិងមានសត្វព្រៃច្រើន ។

វណ្ណៈ:	ចឹងកាលហ្នឹងមានបាញ់ហូបបានទេ?

ធុលៈ	កាលជំនាន់ហ្នឹងមានបាញ់ហូបបានមិនមានពីណាថាអីទេ ។

វណ្ណៈ:	ចឹងអ៊ឹការពារហ្នឹងមានគ្នា៥០០នាក់ហ្នឹងនៅតែមុខច្រកមួយឬមានអ្នកផ្សេងទៀតដាក់រាយតាមព្រំដែនរហូត?

ធុលៈ	កាលហ្នឹងមានទំនាក់ទំនងតគ្នាចឹងទៅ ។

វណ្ណៈ:	ចឹងអ៊ឹមានដឹងថាគេហៅមនុស្សយកទៅបាត់ៗ អ៊ឹមានដឹងទេពេលហ្នឹង?

ធុលៈ	ពេលនោះមានហៅយកមកដាក់គុកអីហ្នឹង ។

វណ្ណៈ:	ដាក់គុកនៅណាវិញ?

ធុលៈ	នៅបាលុងអីហ្នឹង ។

វណ្ណៈ:	ចឹងអ៊ឹគ្រាន់តែដឹង តែមិនដែលឃើញគេចាប់ផ្ទាល់ទេ?

ធុលៈ	បាទ!គ្រាន់តែដឹងទេ ។

វណ្ណៈ:	ចឹងអ៊ឹអត់មានគេធ្លាប់ចាប់ទេ?

ធុលៈ	ខ្ញុំមិនអីទេ អ្នកថ្មីសុទ្ធ ។

វណ្ណៈ:	ចឹងចាប់ភាគច្រើនអតីតអ្នកចាស់ចូលមុនតាំងពីឆ្នាំ៧០-៧១-៧២អីហ្នឹងទេ?

ធុលៈ	បាទ!ហ្នឹងហើយ អ្នកណាធ្វើអាក្រក់ហាមលួច ហាមអីហ្នឹងនៅតែលួចចឹង ។

វណ្ណៈ:	ចឹងយើងទៅដល់ហ្នឹងយើងលួចធ្វើអីទៀតមកពីមានការខ្វះខាតឬមួយយ៉ាងម៉េច?

ធុលៈ	កាលហ្នឹងមានខ្វះខាតអីខ្លះចឹង មុនដំបូងគេយកទៅអប់រំចឹងណាបើយើងនៅដដែលគេយកទៅតាមដំណើរ ។

វណ្ណៈ៖ ចឹងឆ្នាំ១៩៧៥ តាសារឿន ០៥គាត់នៅកាន់នៅហ្នឹងភ្នាម?

ធុលៈ បាទ ។

វណ្ណៈ៖ ចឹងតាសាន ០៦គាត់មានទៅហ្នឹងដែរ?

ធុលៈ តាហ្នឹងគាត់នៅខេត្តមណ្ឌលគិរីតើ ។

វណ្ណៈ៖ តែពុចថាដំបូងទៅហ្នឹងដែរ តែក្រោយមកបំបែកទៅមណ្ឌលគិរី?

ធុលៈ បែបចឹងមែន ទ័ពចាស់គេដឹង យើងអ្នកថ្មីមិនសូវដឹង ។

វណ្ណៈ៖ ចឹងកាលអ៊ីចូលតាំងពីឆ្នាំ៧៥ហ្នឹងរហូតទៅដល់ខេត្តរតនគិរីហ្នឹង អ៊ឹមានដេលសុំគេមកលេង ស្រុកកំណើតវិញទេ?

ធុលៈ អត់ហ៊ានទេ អត់ហ៊ានសុំទេ ។

វណ្ណៈ៖ ចឹងអ៊ីកាលហ្នឹងអត់មានឈឺចាញ់អីហ្នឹងគេទេ?

ធុលៈ ខ្ញុំឈឺដែលញាក់ក្ដៅៗតែដាក់សេរ៉ូមបាត់ សំណាងដែលគេងាប់គ្រប់គ្នា ខ្ញុំបេះអត់អីដែរ ។

វណ្ណៈ៖ ចឹងកាលនៅក្នុងព្រៃការពារចឹងយើងមានធ្វើជាជីរកជាបន្ទាយអីយ៉ាងម៉េចទេ?

ធុលៈ បេះឧទាហរណ៍ថាយើងនៅជាប់មាត់ទន្លេជិតកន្លែងកងពលហ្នឹងយើងធ្វើបន្ទាយទីតាំងតែម្ដង ធ្វើផ្ទះហែរៗចឹងទៅ តែដល់ទៅព្រំដែនវាផ្សេង យើងគ្រាន់តែធ្វើជាជីរកសម្រាប់នៅណា ។

វណ្ណៈ៖ ចឹងកាលហ្នឹងឡាវមានដើរចូលមកលុកលុយមានបាញ់គ្នាទេ?

ធុលៈ ឡាវ មានចូលមកម្ដងដែលមកលួចបាញ់កងនោះងាប់ពីរបីនាក់ ។

វណ្ណៈ៖ យើងដើរចូលដីឡាវឬមួយយ៉ាងម៉េច?

ធុលៈ ដីយើងនៅខាងព្រំដែន វាដើរលបមកបាញ់ ។

វណ្ណៈ៖ ចឹងយើងអត់មានបាញ់តបតវិញទេ?

ធុលៈ កាលហ្នឹងមិនដឹងតបតមិនតបតពេលហ្នឹងខ្ញុំនៅក្រោយគេនៅមុខនោះ គេយកមកដល់វីនសៃ មិនថាបាញ់មិនបាញ់ ។

វណ្ណៈ៖ ចឹងអ៊ីនៅហ្នឹងរហូតដល់ឆ្នាំ១៩៧៩វៀតណាមចូលដល់តែម្ដងឬមួយយ៉ាងម៉េច ពេលវៀត ណាមជិតចូលហ្នឹងមានបាញ់គ្នាដូចខាងស្វាយរៀងព្រៃវែងអីទេ បាញ់តបតជាមួយវៀត ណាមដេលឬមួយអត់ទេ?

ធុលៈ បាញ់គ្នាដែរ ។

វណ្ណៈ៖ ចឹងរយៈពេលបីឆ្នាំហ្នឹងអាវុធទាំងអស់ហ្នឹងបានមកពីប្រទេសណាជាអ្នកជួយ?

ធុលៈ ជំនាន់ហ្នឹងមិនដឹងជាប្រទេសណា ។

វណ្ណៈ៖ មានអាវុធទំនើបទេ?

ធុលៈ មានអាវុធអាកា មានបេ មានឡង់មានអីច្រើនដែរ ។

វណ្ណៈ ចឹងពេលដឹងថាវៀតណាមវាយចូលដល់ប្រទេសកម្ពុជាហើយអ៊ីមានគំនិតចង់មកផ្ទះទេនៅឆ្នាំ ១៩៧៩ហ្នឹង?

ធុលៈ ចង់ដែលតែមិនហ៊ាន ឆ្ងាយពេលមិនស្គាល់ផ្លូវ មិនដឹងជាទៅតាមណាយើងនៅក្មេងយើងម៉េចស្គាល់ ។

វណ្ណៈ ចឹងយើងត្រូវសម្រេចចិត្តដើរទៅតាមអង្គភាព?

ធុលៈ បាទ!ដើរតាមអង្គភាព បើយើងមកខ្លាចវង្វេងតាមផ្លូវឬខ្លាចប្រជាជនកាប់ចោលដឹងធ្វើយ៉ាងម៉េច ។

វណ្ណៈ កាលហ្នឹងអ៊ីអត់មានបានដឹងថាប្រជាជននៅខាងក្រោយគេសម្លាប់អីទេ អត់បាយអត់អាហារអ៊ីអត់ដឹងទេ?

ធុលៈ អត់ដឹងទេ ។

វណ្ណៈ ចឹងពេលដែលកងទ័ពវៀតណាមចូលមកហ្នឹង តើកម្លាំងទ័ពរបស់អ៊ីហ្នឹងវិវត្តទៅខាងណាទៀតឬមួយនៅក្នុងខេត្តរតនគីរីដដែល?

ធុលៈ ដល់នេះចល័តឡើងមកដល់មុំបី ទន្លេល្ពៅហ្នឹងឡើងមកហ្នឹង ។

វណ្ណៈ ចឹងមុំបីហ្នឹងគេហៅ៨០៨ហ្នឹងមិនមែន?

ធុលៈ មិនមែនទេ៨០៨មកខាងនេះទៀតទេ ។

វណ្ណៈ ចឹងពេលឡើងទៅដល់មុំបីហ្នឹងមានគ្នាប៉ុន្មាននាក់ទៅដល់ហ្នឹង?

ធុលៈ កន្លែងមានថៃ ឡាវ ខ្មែរ បានគេហៅថាមុំបី ។

វណ្ណៈ ចឹងខ្មែរយើងហៅអី ហៅមុំបីដែរ?

ធុលៈ វាមិនដឹងថាហៅអីទេ យើងហៅមុំបី ព្រោះមាន ថៃ ឡាវ ខ្មែរ ។

វណ្ណៈ ចឹងដោយសារមាន ថៃ មានឡាវ មានខ្មែរ ចឹងបង្កើតចេញជាពាក្យមុំបី?

ធុលៈ បាទ ។

វណ្ណៈ ចឹងពីណាគេជាអ្នកកំណត់ចឹង?

ធុលៈ មិនដឹងអី ខ្ញុំថាចឹងតែម្តង ព្រោះមានថៃឡាវខ្មែរ តែគេហៅមុំបីដូចគ្នាដែរ ។

វណ្ណៈ ចឹងកន្លែងហ្នឹងដូចជាកន្លែងណាត់ជួបគ្នាចឹង ខាងឡាវ ខាងខ្មែរខាងថៃអីមក?

ធុលៈ អត់មានណាត់ទេ វាជាព្រំប្រទល់ ។

វណ្ណៈ ចឹងព្រំប្រទល់មុំបី?

ធុលៈ បាទ!មុំបីវាចឹង ។

វណ្ណៈ: ចឹងពេលមកដល់មុំបឹហ្នឹង មកដល់ដំបូងហ្នឹងមានជួបពីណាខ្លះ មានបានជួបតាម៉ុកអីទេ?

ធុលៈ នៅទេ តែមេៗខាងក្រោមគេមកនៅហ្នឹងមុនហើយ ។

វណ្ណៈ: មានមេណាខ្លះ?

ធុលៈ ភ្លេចអស់ហើយដល់យូរពេក ។

វណ្ណៈ: ចឹងពេលអ៊ឹមកដល់មុំបឹហើយមានចេញទៅណាទៀតទេ?

ធុលៈ ដល់ពេលវៀតណាមវាវាយយើងចេញ ។

វណ្ណៈ: ចេញទៅខាងណាវិញ?

ធុលៈ ចេញធ្លាក់ទៅនៅដីថៃ ។

វណ្ណៈ: ចឹងកាលហ្នឹងអ៊ំនៅកងពល៨០១ដដែលឬមានការផ្លាស់ប្តូរហើយ?

ធុលៈ នៅកងពល៨០១ដដែល ។

វណ្ណៈ: ពីណាគេដឹកនាំនៅហ្នឹង?

ធុលៈ ៨០១ហ្នឹងតាសារឿន ដដែលហ្នឹង ។

វណ្ណៈ: ចឹងគាត់តាមទ័ពរហូត?

ធុលៈ បាទ ។

វណ្ណៈ: ចឹងពេលនៅដីថៃ ចឹងខ្ញុំចង់ឲ្យអ៊ំរៀបរាប់បន្តទៀតពេលចូលដីថៃអស់រយៈពេលប៉ុន្មានហើយ យើងរៀបចំកម្លាំងមកវាយជាមួយវៀតណាមវិញវាយជាមួយទាហានខាងរដ្ឋាភិបាលវិញ នៅតំបន់ប្រកណាខ្លះ អាចរៀបរាប់បានទេ?

ធុលៈ វាមិនសូវច្បាស់ទេ តាមពិតម្តុំមុំបឹនៅដីឡាវហ្នឹងប្រកព្រះនន្ទ័លព្រហ្មព្រះឥន្ទអីហ្នឹង ប្រកឡាវចាំច្បាស់នៅហ្នឹង ។

វណ្ណៈ: ចឹងអ៊ំវាយនៅហ្នឹងរហូតឬវាយទៅខាងណាទៀត រហូតមកដល់ភ្នំដងរែកអន្លង់វែងអីនេះ ជួបតាម៉ុកអីហ្នឹង អ៊ំបានមកដល់អន្លង់វែងហ្នឹងដែរឬមួយនៅមុំបឹរហូតឬយ៉ាងម៉េច?

ធុលៈ ចឹងកាលនៅមុំបឹហ្នឹង មានតាសុន សេន ។

វណ្ណៈ: មុំបឹតាសុន សេន ហើយយ៉ាងម៉េចទៀត?

ធុលៈ បើកអង្គរឡើកងទ័ពហើយមីងៗនៅលើគាត់ហ្នឹង ។

វណ្ណៈ: ចឹងមានឃ្លាំងនៅហ្នឹង?

ធុលៈ បាទ!ឃ្លាំងមាននៅហ្នឹង ។

វណ្ណៈ: ចឹងតាម៉ុក គាត់កាន់ទ័ពផ្សេងទៅ?

ធុលៈ បាទ! ។

វណ្ណៈ: ចឹងតាសុន សេន គាត់ខាងឃ្លាំងទៅ?

ធុលៈ: គាត់ទ័ពជងកន្លែងណានេះមានមេមានទ័ព មានស្បៀងអាហារដូចគ្នា ។

វណ្ណៈ: ចឹងអ៊ីមានចុះមកវាយជាមួយកម្លាំងខាងរដ្ឋាភិបាលទេជាមួយវៀតណាមអីហ្នឹងវាយគ្នាយ៉ាងម៉េចដែលពេលហ្នឹង យើងមានវិធីសាស្ត្រអីដើម្បីវាយជាមួយរដ្ឋាភិបាល?

ធុលៈ: កាលហ្នឹងវាយភាគច្រើនជាមួយវៀតណាមទេ មិនសូវវាយជាមួយទាហានខាងរដ្ឋាភិបាលទេ វាយជាមួយកងទ័ពវៀតណាមនៅហ្នឹងចឹង ពួកខ្ញុំវាយនៅហ្នឹងតែម្តង ។

វណ្ណៈ: ចឹងឲ្យតែដឹងវៀតណាមនៅកន្លែងណាវាយកន្លែងហ្នឹងតែម្តង?

ធុលៈ: បាទ! វាយកាលហ្នឹងយើងមិនវាយជាកម្លាំងធំណា វាយកម្លាំងមួយក្រុមពីរក្រុមចឹងទៅ ។

វណ្ណៈ: ចឹងកម្លាំងវាយឆ្មក់?

ធុលៈ: បាទ! ដើរធ្វើការចឹងទៅឃើញយួនកន្លែងណាវាយកន្លែងហ្នឹងទៅ ។

វណ្ណៈ: ចឹងអាហារស្បៀងអីគេយកឲ្យយើងអត់មានខ្វះខាតទេ?

ធុលៈ: បាទ ។

វណ្ណៈ: ចឹងជំនួយកាលហ្នឹងមកពីខាងណាអ៊ីមានដឹងទេ?

ធុលៈ: ជំនួយយកមកពីចិន ។

វណ្ណៈ: ចឹងទាំងកាំភ្លើងទាំងសំភារៈហូបចុកទាំងអស់?

ធុលៈ: បាទ ។

វណ្ណៈ: ចឹងយើងយកមកឆ្លងកាត់តាមប្រទេសថៃ?

ធុលៈ: បាទ ។

វណ្ណៈ: ចឹងកាលវាយជាមួយវៀតណាមហ្នឹង ចឹងវៀតណាមអីមានគ្រោះថ្នាក់ច្រើនទេ?

ធុលៈ: អាហ្នឹងវាពិបាកដែលជួនណាប្រជាជនថាងាប់ច្រើនទៅ ជួនណាយើងឃើញងាប់តិចទៅ យើងមិនបានមើលឃើញជាក់ស្តែងថាឃើញងាប់ប៉ុន្មានអត់ទេ មិនបានឃើញជាក់ស្តែងទេ កាលហ្នឹង ។

វណ្ណៈ: ចឹងដឹងតាមរយៈប្រជាជនប្រាប់វិញ?

ធុលៈ: បាទ! ដឹងតាមរយៈប្រជាជនវិញ ជួនណាគាត់ថាងាប់ពី១០ ទៅ២០ នាក់ចឹងទៅ ជួនកាលងាប់ពីរបីទៅដឹងពីគាត់មកវិញទេ បើយើងវាយឃើញងាប់ជាក់ស្តែងឃើញប៉ុន្មានថាប៉ុណ្ណឹងទៅ ។

វណ្ណៈ: ចឹងខាងខ្មែរក្រហមវាយចល័តចឹងបែបមិនសូវមានគ្រោះថ្នាក់ទេតាមមើល?

ធុលៈ: មិនសូវដែរ ។

វណ្ណៈ យើងវាយដក?

ធុលៈ វាយដកៗពីរបីនាក់ ។

វណ្ណៈ ចឹងកម្លាំងយើងមានតែ១០នាក់អាចវាយកម្លាំងវៀតណាម៥០នាក់អីចឹង?

ធុលៈ បាទ ។

វណ្ណៈ បើសិនជាងាប់ក៏តិច?

ធុលៈ ងាប់តិច អូនឯងបីនាក់ចឹងទៅ ខ្ញុំបីនាក់ចឹងទៅដាក់មួយប្រាវគេចទៅ ។

វណ្ណៈ ចឹងនិយាយវាយគេចមិនមែនវាយបុកទៅមុខទេ?

ធុលៈ វាយគេចមិនមែនវាយរុលទៅមុខទេ តែវាយរហូត ។

វណ្ណៈ ចឹងយើងវាយបុកទៅមុខកម្លាំងយើងតិច?

ធុលៈ កម្លាំងយើងវាតិច ។

វណ្ណៈ ចឹងបើមានកម្លាំងខ្មែរឡើងតាមចឹងយើងអត់មានស្មាក់វាយទេ?

ធុលៈ មិនដឹងដែលថានណាខ្មែរអីទេ ដល់ពេលនៅព្រៃដូចគ្នា ។

វណ្ណៈ ចឹងកាលហ្នឹងអឺមានខ្លាចទេ មានមីនផងមានសត្វព្រៃផង បាញ់គ្នាអីផងមានការភ័យខ្លាចទេកាលហ្នឹង?

ធុលៈ មានបារម្ភណ៍ដែរ មិនគេមិនឯង អារម្មណ៍ចេះតែមាន មិនដឹងជាគ្រោះគេមិនដឹងជាគ្រោះយើង ។

វណ្ណៈ ចឹងអឺនៅមុំបីហ្នឹងដល់ពេលណាបានផ្លាស់ទៅណាទៀត?

ធុលៈ តាំងពីមកខាងអូរត្រាវនេះ ស្រុកថៃ ។

វណ្ណៈ ចឹងអូរត្រាវនៅស្រុកថៃទេ?

ធុលៈ បាទ ។

វណ្ណៈ ចឹងលែងចូលមកវាយហើយ?

ធុលៈ អាហ្នឹងផ្លាស់ផ្ទូមីងៗណាស់ មីងៗក្មេងៗអស់ហ្នឹង តែផ្នែកកងទ័ពមកដដែល ។

វណ្ណៈ ចង់និយាយអឺមកនៅខាងណា?

ធុលៈ ខ្ញុំអត់មានមកវាយទេ ខ្ញុំនៅក្រោយ ខ្ញុំនៅជាមួយមីងៗវិញ ។

វណ្ណៈ ក្រែងអឺកម្លាំងពេញហេតុម៉េចបានជាទៅនៅជាមួយមីងៗវិញ?

ធុលៈ កាលហ្នឹងខ្ញុំត្រូវដៃពិកាទៅខ្ញុំលែងឡើងវាយ ។

វណ្ណៈ ចឹងពេលយើងពិកាត្រូវរបួសអីចឹងគេលែងឲ្យទៅមុខហើយ?

ធុលៈ បាទ ។

វណ្ណៈ	ចឹងកម្មាំងនៅជាមួយមីងៗហ្នឹងធ្វើអីទៅ?

ធុលៈ	គាត់មានធ្វើអី គាត់ដាំដំឡូងដាំចេកអំពៅរបស់គាត់ហូបទៅជុំវិញទីតាំងផ្ទះចឹងទៅ តែអង្ករបើកហូប ។

វណ្ណៈ	គាម៉ុកគាត់បើកឲ្យ?

ធុលៈ	បាទ ។

វណ្ណៈ	ចឹងនៅណាមិញនៅអូរត្រាវ?

ធុលៈ	អូរត្រាវ ។

វណ្ណៈ	អូរត្រាវជាប់ព្រំដែនខ្មែរថៃ?

ធុលៈ	អត់ទេ ចូលទៅជ្រៅដែរ ។

វណ្ណៈ	ហេតុអីបានជាយើងមិនដាក់កម្មាំងនៅលើដីយើង?

ធុលៈ	ដីយើងបើយួនទៅដល់ហ្នឹងហើយ បាញ់ផាប់អស់ ទាល់តែដាក់ទៅជ្រៅ ។

វណ្ណៈ	ចឹងយើងនៅដីថៃយើងដួលដែរ?

ធុលៈ	មិនដឹងជាយ៉ាងម៉េចកាលហ្នឹង ខាងលើគេអ្នកសម្រេចខ្ញុំមិនដឹងដែរ ។

វណ្ណៈ	ចឹងអូរត្រាវខាងដីថៃហ្នឹង អ៊ំបញ្ជាក់ខ្ញុំបានទេថានៅម្តុំណា ទីតាំង?

ធុលៈ	ខ្ញុំមិនបានដឹងច្បាស់ដឹងថាអូរត្រាវៗ ។

វណ្ណៈ	នៅជួរអន្លង់វែងដែរឬមួយនៅខាងម៉ាឡៃអីទេ?

ធុលៈ	អត់ទេ នៅជួរអន្លង់វែងនេះ ។

វណ្ណៈ	ឆ្នាំណាដែលអ៊ំនៅហ្នឹង?

ធុលៈ	ភ្លេចហើយមិនដឹងជាឆ្នាំណាទេ ។

វណ្ណៈ	ចឹងអ៊ំពិការឆ្នាំណាដែរ?

ធុលៈ	ខ្ញុំពិការឆ្នាំ៨៧ ។

វណ្ណៈ	ឆ្នាំ៨៧ហ្នឹងវៀតណាមដិតដកហើយ?

ធុលៈ	បាទ ។

វណ្ណៈ	ចឹងអ៊ំមានដឹងថាវៀតណាមដកនៅឆ្នាំណាទេ?

ធុលៈ	ខ្ញុំអត់បានចាំផង ។

វណ្ណៈ	វៀតណាមដកតាមឯកសារអីហ្នឹងដកនៅឆ្នាំ១៩៨៩?

ធុលៈ	ចឹងតាមឯកសារច្បាស់ហើយខ្ញុំអត់បានចាប់អារម្មណ៍ទេចឹងៗ ចំណុចយើងនិយាយបាននិយាយចំណុចនិយាយមិនបានមិននិយាយ ។

វណ្ណៈ ចឹងពេលដែលវៀតណាមដកហើយខាងជំនួយចិនគេលែងផ្តល់ឲ្យពូមានដឹងទេ?

ធុលៈ បាទ!ចឹងហើយ ។

វណ្ណៈ ព្រោះកាលហ្នឹងមានខ្មែរវាយខ្មែរហើយ?

ធុលៈ បាទ ។

វណ្ណៈ អ៊ឹមានបានជួបតាម៉ុក ផ្ទាល់ទេ?

ធុលៈ ជួបស្គាល់ ។

វណ្ណៈ ចឹងស្គាល់គាត់ច្បាស់?

ធុលៈ បាទ ។

វណ្ណៈ គាត់ជាមនុស្សយ៉ាងម៉េចដែរ តាម៉ុក?

ធុលៈ មនុស្សគាត់ជាមនុស្សសាមញ្ញាទេតាមមើល ។

វណ្ណៈ គាត់មានកាចអីទេ?

ធុលៈ កាចវ៉ូងវាំងចឹង តែជួបមានអីសុំអីឲ្យហ្នឹងតែម្តង អូនឯងឃើញមាននាឡិកាអី តាសុំនាឡិកាមួយមក ដោះពីដៃឲ្យភ្លែត ។

វណ្ណៈ អ៊ឹមានដែលនិយាយលេងជាមួយគាត់ទេ?

ធុលៈ អត់ដែលហ៊ានទេ ។

វណ្ណៈ ចឹងកាលហ្នឹងអ៊ឹនៅអូរត្រាវរហូតឬមួយអ៊ឹផ្លាស់ដូរមកលើភ្នំនេះទៀត?

ធុលៈ ខ្ញុំនៅអូរត្រាវហ្នឹងក្រោយមកគេបញ្ជូនឲ្យទៅនៅជំរំវិញ មកនៅជំរំខ្ញុំចុះមកជំនាន់អ៊ុនតាក់ហ្នឹងបណ្តោយ ។

វណ្ណៈ ចឹងជំនាន់អ៊ុនតាក់អ៊ឹមកនៅណាវិញ?

ធុលៈ ជំនាន់អ៊ុនតាក់ខ្ញុំចុះទៅស្រុកខ្មែរ ។

វណ្ណៈ ទៅខ្មែរនៅកន្លែងណា?

ធុលៈ ទៅខេត្តតាកែវមិញនេះ ខ្ញុំទៅជាប្រជាជនវិញហើយ ។

វណ្ណៈ ឆ្នាំ១៩៩៣?

ធុលៈ ខ្ញុំចុះទៅស្រុកកំណើតជំនាន់អ៊ុនតាក់ ។

វណ្ណៈ ចឹងឆ្នាំ១៩៩៣ហ្នឹងអ៊ឹចេញពីជំរំទៅខេត្តតាកែវវិញ?

ធុលៈ កាលហ្នឹងអ៊ុនតាក់ដឹកទៅ កាលហ្នឹងបោះឆ្នោតត្រូវគ្នាហើយ ។

វណ្ណៈ ចឹងកាលហ្នឹងអ៊ុនតាក់ដឹកទៅដល់ស្រុកបានបោះឆ្នោតនៅស្រុកចឹង?

ធុលៈ បាទ ។

វណ្ណៈ	ចឹងហេតុអីបានជាអ៊ំត្រឡប់មករស់នៅនេះវិញ?

ផុលៈ	ខ្ញុំត្រឡប់មកវិញ ព្រោះនៅនោះអត់មានទឹកដី ។

វណ្ណៈ	ហើយម៉ែឪស្លាប់អស់ទៀត?

ផុលៈ	បាទ!ចឹងយើងមិនមករកដីវិញ អាហ្នឹងដើម្បីរស់ ។

វណ្ណៈ	ចឹងអ៊ំបានត្រឡប់មកដល់នេះវិញនៅឆ្នាំណា?

ផុលៈ	ឆ្នាំ១៩៩៩ ។

វណ្ណៈ	ចឹងឆ្នាំ៩៩សមាហរណ៍កម្មហើយមក?

ផុលៈ	បាទ!សមាហរណ៍កម្មហើយមក ។

វណ្ណៈ	ចឹងឆ្នាំ៩៩មកនៅភូមិនេះគេហៅភូមិអី?

ផុលៈ	ភូមិទំនប់ដាច់ ។

វណ្ណៈ	ឃុំ?

ផុលៈ	ទំនប់ដាច់ ស្រុកត្រពាំងប្រាសាទ ខេត្តឧត្តរមានជ័យ ។

វណ្ណៈ	ចឹងឆ្នាំ៩៩មកនៅនេះវិញ?

ផុលៈ	បាទ ។

វណ្ណៈ	ចឹងមានដីមានស្រែធ្វើច្រើននៅនេះ?

ផុលៈ	បាទ!បានរស់ស្រួល ។

វណ្ណៈ	បានចែកកូនចៅ?

ផុលៈ	បាទ ។

វណ្ណៈ	ចឹងអ៊ំមានដីប៉ុន្មានហិចតាដែរ?

ផុលៈ	មាន១០ហិចតាដែរ ។

វណ្ណៈ	ចឹងអត់មានប៉ះពាល់ជាមួយក្រុមហ៊ុនអី?

ផុលៈ	អត់មានប៉ះទេ ។

វណ្ណៈ	ចឹងអ៊ំមានបានទទួលធ្វើប្លង់ហើយនៅ?

ផុលៈ	នៅទេ ។

វណ្ណៈ	ចឹងមិនទាន់មានក្រុមនិសិត្សចុះមកដល់នេះទេ?

ផុលៈ	មានចុះមកហើយតែមិនទាន់បានធ្វើនៅឡើយ ។

វណ្ណៈ	ចឹងបើបានធ្វើហើយយើងបានកម្មសិទ្ធិរឹងមាំ?

ផុលៈ	បាទ ។

វណ្ណៈ៖ ចឹងខ្ញុំចង់សួរៗខ្លះៗទៀតសម័យតស៊ូសម័យក្រោយឆ្នាំ៧៩អីហ្នូវហែរមកចឹង អ៊ីមានបានដឹងថា តាម៉ុក បានធ្វើផ្លូវពីអន្លង់វែងទៅដល់ប្រាសាទព្រះវិហារអីទេ ហើយផ្លូវចុះពីលើភ្នំនៅឆ្នាំណាអ៊ីមានបានដឹងអ៊ីមានចាំទេ ។

ធុលៈ ខ្ញុំមិនបានចាំច្បាស់ទេ រឿងហ្នឹង មិនដឹងជាគាត់ធ្វើប្រកណាខ្លះ ។

វណ្ណៈ៖ តែដឹងថាតាម៉ុកធ្វើ?

ធុលៈ បាទ ។

វណ្ណៈ៖ ចឹងនៅលើប្រាសាទក្រោយឆ្នាំ៧៩ឆ្នាំ៨០ជាងអី កាលសម័យវៀតណាមនៅហ្នឹងអីហ្នឹង តើអ៊ីមានដឹងថានៅលើប្រាសាទមានកងទ័ពថៃឈរជើងឬមួយខាងខ្មែរយើងឈរជើងអ៊ីមានបានដឹងទេ?

ធុលៈ អាហ្នឹងអត់ដឹងដែរ ។

វណ្ណៈ៖ ចឹងអ៊ីធ្លាប់ឆ្លងកាត់នៅក្នុងសម័យខ្មែរក្រហម អ៊ីគិតថាការរស់នៅសម័យខ្មែរក្រហមនិងរស់នៅសម័យឥឡូវនេះ តើអ៊ីយល់ថា សម័យមួយណារស់នៅស្រួលជាងឬក៏យ៉ាងម៉េចដែរបើយើងប្រៀបធៀបសម័យពីរហ្នឹង?

ធុលៈ សម័យពេលហ្នឹងយើងមានបាយហូបចុកខ្លួនឯងចឹង មានម៉ូតូជិះខ្លួនឯងជំនាន់នេះ កាលមុនយើងមានអីជិះអត់ទេ ជំនាន់នេះយើងមានម៉ូតូមានអី អ្នកណាមានទិញឡានជិះក៏បានមានគ្រប់ៗគ្នាទៅ ។

វណ្ណៈ៖ ចឹងអ៊ីគិតថាឥឡូវស្រួលជាង?

ធុលៈ បាទ!ឥឡូវស្រួលជាងមុន មុនដើររហូត ។

វណ្ណៈ៖ ចឹងឥឡូវកូនចៅបានរៀនសូត្រ?

ធុលៈ បានរៀនសូត្រ ។

វណ្ណៈ៖ កូនអ៊ីរៀនដល់ថ្នាក់ណាខ្លះដែរ?

ធុលៈ រៀនបានត្រឹមថ្នាក់ទី១២ ខ្លះថ្នាក់ទី៦ទី៧ ។

វណ្ណៈ៖ ចឹងអ៊ីយល់យ៉ាងម៉េចដែលការដែលជម្រុញកូនឲ្យរៀនសូត្រហ្នឹង គិតថាវាមានផលប្រយោជន៍ឬយ៉ាងម៉េច?

ធុលៈ ចិត្តខ្ញុំគិតថាការរៀនសូត្រវាមានផលប្រយោជន៍ហើយតែវាអត់លុយបន្តទៅទៀតជារឿងរបស់យើង ការចេះដឹងមនុស្សវាល្អហើយ បើអត់ចេះដឹងមនុស្សវាគុស ការចេះដឹងវាល្អដូនណាយើងមានលុយរៀនទៅវារកអនាគតវាបាន ដល់យើងអត់លុយអនាគតក៏អត់ដែរសំខាន់លុយ ។

វណ្ណៈ: ចឹងចំពោះជីវភាពគ្រួសារអ៊ីរាល់ថ្ងៃហ្នឹង មានការលំបាកឬមិនអីទេ?

ធុលៈ មិនអីទេ ម៉ាសមរម្យ ។

វណ្ណៈ: ចឹងដល់រដូវធ្វើស្រែរាល់ឆ្នាំអ៊ីមានដែលពិភាក្សាជាមួយកូនឬប្រពន្ធឬអ្នកជិតខាងថា ឆ្នាំនេះយើងត្រូវធ្វើអីបន្ត ដូចថាឆ្នាំនេះយើងដាំដំឡូង ឆ្នាំក្រោយយើងចង់ដាំពោត ចឹងមានដែលពិភាក្សាទេ?

ធុលៈ ហ្នឹងមានពិភាក្សា ជួនណានិយាយគ្នាថាដាំសណ្តែកសៀងចឹងទៅ ជួនណាដាំជាដំឡូង ដំឡូងអត់កើតទៀតទៅខាតទៀតទៅ ។

វណ្ណៈ: ចឹងពិភាក្សាហ្នឹងនៅពេលណាច្រើនតែពិភាក្សាគ្នានោះ ជាមួយកូនប្រពន្ធច្រើននៅពេលណាដែរ?

ធុលៈ ពិភាក្សាយើងទំនេរអីហ្នឹង ពេលចប់ពីការងារ ថាឆ្នាំនេះត្រូវដាំនេះដាំនោះជួនណាមិត្តភក្តិចឹងទៅគេក៏ដាំយើងក៏ដាំ ថាដាំដំឡូងក៏ដាំទៅកើតមិនកើតជួនណាក៏រលួយអស់ទៅ ។

វណ្ណៈ: ចឹងមានខាងអង្គការក្រៅរដ្ឋាភិបាលហៅយើងទៅប្រជុំរឿងកសិកម្មអីទេ មានមកពន្យល់អីទេ?

ធុលៈ បែបមានតែខ្ញុំមិនសូវបានប្រជុំទេ មានប្រពន្ធអីខ្ញុំមិនសូវដឹងទេ ។

វណ្ណៈ: ចឹងចំពោះអ្នកជិតខាងរាល់ថ្ងៃហ្នឹងមានទំនាស់ទាស់គ្នាឬមានការរាប់អានយ៉ាងម៉េចដែរ?

ធុលៈ រាប់អានដូចបងប្អូនចឹង ។

វណ្ណៈ: អត់មានបញ្ហាអីទេ?

ធុលៈ បាទ!បងប្អូនល្មមៗមិនស្មើទេ ។

វណ្ណៈ: ចឹងនៅនេះមានវត្តប៉ុន្មានដែរ?

ធុលៈ នៅនេះមានវត្តមួយគេហៅវត្តទំនប់ដាច់ ។

វណ្ណៈ: ចឹងអ៊ីកាន់សាសនាអីដែលរាល់ថ្ងៃហ្នឹង?

ធុលៈ កាន់សាសនាព្រះពុទ្ធ ។

វណ្ណៈ: ចឹងអ៊ីយល់យ៉ាងម៉េចដែលបានជាអ៊ីកាន់សាសនាព្រះពុទ្ធចឹង យើងគិតឃើញថាយ៉ាងម៉េចដែរ?

ធុលៈ សាសនាព្រះពុទ្ធទៀងត្រង់ មិនឲ្យមនុស្សអាក្រក់មនុស្សខូច មនុស្សកាប់ចាក់គ្នាលួចប្លន់គ្នាចឹងគេប្រដៅយើងឲ្យល្អ តែយើងចេះកាងលិចកាងកើតជារឿងរបស់យើង អ្នកឯងទទួលផលរបស់អ្នកឯងទាន់ហន់ភ្លាមទៅ គេចាប់ដាក់គុកច្រវ៉ាក់ជារឿងរបស់អ្នកឯង បើអ្នកធ្វើល្អ

តាមព្រះពុទ្ធត្រឹមត្រូវទៅ បើជាន់ជើងគេសំពះគេទៅ បើគេវាយក៏វាយទៅបើគេមិនវាយគេយល់ថាព្រះពុទ្ធហើយអាហ្នឹង ។

វណ្ណៈ ចឹងសាសនាជួយតម្រង់ផ្លូវចិត្តយើងឲ្យធ្វើអំពើល្អ?

ធុលៈ បាទ!សាសនាព្រះពុទ្ធតាំងពីដើមមកធ្វើឲ្យល្អតើ តែបើនិយាយពីព្រះពុទ្ធខ្ញុំមិនចេះអីច្រើនទេ តែការយល់ដឹង ខ្ញុំមិនបានបួសមិនបានសូត្រគេទេ គ្រាន់តែការយល់ដឹងទេ គេមិនឲ្យកាប់ចាក់ តែអ្នកឯងកាប់ចាក់អាហ្នឹងយើងទទួលផលបាបហើយ បើយើងធ្វើល្អទៅមិនបាបទេ អាហ្នឹងដូចព្រះពុទ្ធហើយល្អ បើគេវាយពីរដៃយើងរត់ចេញសិនទៅសើច....។

វណ្ណៈ ចឹងយើងកុំទៅលួចទៅប្លន់គេ?

ធុលៈ បាទ ។

វណ្ណៈ ចឹងយើងរស់នៅរាល់ថ្ងៃហ្នឹងយើងមានរដ្ឋាភិបាលយើងមានច្បាប់ ចឹងបើមានអ្នកធ្វើខុសអីចឹងតើច្បាប់យើងអាចដោះស្រាយបានទេ បើតាមអ៊ីយល់ច្បាប់យើងរាល់ថ្ងៃល្អដែរ?

ធុលៈ បាទ!ការដោះស្រាយតែខ្ញុំមិនដែលមានរឿងរ៉ាវអីទេ មិនដឹងថាដោះស្រាយយ៉ាងម៉េច ។

វណ្ណៈ អ៊ីមិនដែលមានទេ តែបើថ្ងៃក្រោយទៅដូចអ្នកជិតខាងមានទំនាស់ដីធ្លីឬអីមួយចឹងអ៊ីអាចថាមានសង្ឃឹមពឹងពាក់ទៅលើផ្នែកច្បាប់បានដែលអត់ឬមួយអ៊ីគិតថាច្បាប់រាល់ថ្ងៃហ្នឹងមិនកើតទេ រាល់ថ្ងៃមានច្បាប់តែមិនមានអ្នកគោរព ដូចថាអ្នកមានចេះតែឈ្នះចឹងទៅ បើចិត្តអ៊ីគិតថាចឹងមែនឬអ៊ីគិតថាច្បាប់គេល្អដែរឬយ៉ាងម៉េច?

ធុលៈ ចិត្តខ្ញុំសព្វថ្ងៃសង្ឃឹមលើច្បាប់ហ្នឹងហើយ បើច្បាប់ថាឲ្យយើងត្រូវយើងត្រូវទៅ បើច្បាប់ឲ្យខុសៗហើយតាមចិត្តខ្ញុំមានការយល់ដឹងចឹង សំខាន់យើងសង្ឃឹមលើច្បាប់ បើច្បាប់ថាខុសអាហ្នឹងរឿងច្បាប់តើ បើយើងខុសហើយថាល្អអាហ្នឹងជារឿងរបស់ច្បាប់តើ ជាអ្នកវិនិច្ឆ័យខាងហ្នឹង ។

វណ្ណៈ ចឹងនៅម្តុំនេះសុទ្ធតែខ្មែរៗយើងរស់នៅអីចឹង បើសិនជាថ្ងៃក្រោយឬថ្ងៃនេះមានជនបរទេសមកទិញដីរស់នៅជិតហ្នឹង ដូចជាជនអន្តោប្រវេសមករស់នៅជិតយើង គេមានលុយទិញប៉ុន្តែគេមិនប្លន់យើងទេ គេមកទិញរស់ជិតយើង តើអ៊ីសប្បាយចិត្តទេ បើសិនជាមិនមែនខ្មែរជាអ្នកផ្សេងអីចឹង?

ធុលៈ ខ្ញុំអត់សប្បាយទេ បើជាខ្មែរគ្នាឯងសប្បាយ ។

វណ្ណៈ ចឹងបើជាជនជាតិវៀតណាមឬជនជាតិថៃមករស់នៅក្បែរយើងគឺយើងមិនសប្បាយចិត្ត?

ធុលៈ បាទ!ព្រោះគ្នាយើងស្រួលនិយាយគ្នាស្តាប់បានបើខុសគ្នាខ្ញុំពិបាកចិត្ត មិនដឹងជានិយាយអីយ៉ាងម៉េច ។

វណ្ណៈ៖ ចឹងបើនិយាយពីផលដំណាំដែលយើងធ្វើបានដូចជាដំឡូងចឹងយើងយកទៅលក់នៅណា?

ធុលៈ ថៅកែគេមកទិញ ខ្ញុំធ្វើតែម្ដងដល់ធ្វើលែងបានខ្ញុំលែងធ្វើហើយ ។

វណ្ណៈ៖ ចឹងធ្វើអត់ចំនិញ?

ធុលៈ បាទ! ធ្វើខាត វារលួយដូចថាពីរហាត់ចឹងទៅនៅសល់ពីបីរៃក្រៅពីហ្នឹងរលួយអស់ អត់មានមើម ចឹងបេះតែខ្ចិលទៅ ចឹងអត់សូវរីកចំរើនដែរ ។

វណ្ណៈ៖ ចឹងនៅស្រុកស្រែចម្ការភ័យបំផុតនៅពេលយើងធ្វើដំណាំអត់បាន?

ធុលៈ បាទ ។

វណ្ណៈ៖ ដូចជាពោតសណ្ដែកអីបើយើងធ្វើបានហើយថោកយើងភ័យហើយ?

ធុលៈ អាហ្នឹងភ័យ ។

វណ្ណៈ៖ ដូនកាលយើងមិនមានលុយខ្លួនឯងទៅធ្វើយើងខ្ចីលុយធនាគារគេដែលយើងត្រូវចំពាក់គេ?

ធុលៈ បាទ! ជំពាក់គេ ។

វណ្ណៈ៖ ចឹងជំពាក់គរហូតអាចឲ្យមានបញ្ហា?

ធុលៈ បាទ! ជំពាក់គរហូត ។

វណ្ណៈ៖ ចឹងចិត្តអ៊ឹរាល់ថ្ងៃចង់សំណូមពរដល់រាជរដ្ឋាភិបាលឬសមាគមន៍អង្គការអីផ្សេងៗឲ្យជួយផ្នែកខាងកសិកម្មហ្នឹងដែលអត់?

ធុលៈ ឲ្យគេជួយកសិកម្មខាងអី ។

វណ្ណៈ៖ ឲ្យគេជួយមកណែនាំ ដូចថាអ៊ឹធ្វើផលបានឲ្យគេជួយបង្ហាញឲ្យលក់មានតម្លៃទីផ្សារខ្ពស់អី អ៊ឹចូលចិត្តអ៊ឹសប្បាយចិត្តទេបើសិនជាមានចឹង?

ធុលៈ បើមានចឹងខ្ញុំសប្បាយចិត្ត ឲ្យមានទីផ្សារតម្លៃខ្ពស់ដែលអាចឲ្យប្រជាជនបន្តកសិកម្មហ្នឹងបានតទៅទៀត ដែលអាចសង្ឃឹមបានអាហ្នឹងបេះតែមានទឹកចិត្តហើយទាំងគេទាំងខ្ញុំ បើថោកធ្វើគ្រាន់ឲ្យឈ្នួលទៅគេវិញអស់រលីង ។

វណ្ណៈ៖ ចឹងខ្ញុំដូចជាអត់មានអីសួរអ៊ឹទៀតហើយ ចឹងខ្ញុំអរគុណអ៊ឹច្រើនហើយ អ៊ឹមានអ៊ីចង់បន្ថែមទៀតទេអ៊ឹ?

ធុលៈ អត់មានអីទេ ។

វណ្ណៈ៖ ចឹងខ្ញុំអរគុណ ។

ធុលៈ បាទ ។

**ចប់**